វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ១១៦ ប្រក /ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាសស្តីពីការរៀបចំលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីខេត្តព្រះវិហារ និងសមាសភាពគណៈកម្មការសុរិយោដីស្រុកក្នុងខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត.ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- យោងប្រកាសលេខ០៧៧ ប្រកចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង
- តាមសំណើររបស់គណៈកម្មការសុរិយោដីខេត្តព្រះវិហារ

**សំរេច**

ប្រការ ១ :

ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីខេត្តព្រះវិហារដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក សំ សារឿន | អនុប្រធានមន្ទីរ ដនសស.ខេត្តព្រះវិហារទទួលបន្ទុកការងារសុរិយោដី | ជាប្រធាន |
| ២- លោក សាន រតនៈ | ប្រធានការិយាល័យសុរិ.និងភូមិសាស្ត្រមន្ទីរដនសស.ព្រះវិហារ | ជាអនុប្រធាន |

ប្រការ ២ :

ត្រូវបានរៀបចំសមាសភាពគណៈកម្មការសុរិយោដីស្រុកក្នុងខេត្តព្រះវិហារ ដូចខាងក្រោម :

ក- គណៈកម្មការសុរិយោដីស្រុកត្បែងមានជ័យៈ

| | | |
|---|---|---|
| ១- លោក ហាក់ ប៊ុនហួន | ប្រធានការិយាល័យ.ដនសភ.ស្រុកត្បែងមានជ័យ | ជាប្រធាន |

ខ-គណៈកម្មការសុរិយោដីស្រុករវៀង

| | | |
|---|---|---|
| ១-លោក សេន សុផាត | ប្រធានការិយាល័យ ដនសភ.ស្រុករវៀង | ជាប្រធាន |

Downloaded from http://www.khmerlaws.com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ប្រការ ៣ :

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុង គណៈកម្មការសុរិយោដីខណ្ឌទាំងអស់ក្នុងខេត្តព្រះវិហារមានបេសកកម្ម អនុវត្តនូវភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុក្រឹត្យ លេខ ៤៧ អនប្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រការ ៤:

នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីខេត្ត ព្រះវិហារប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តព្រះវិហារ អស់លោកដូចមានរាយនាមក្នុងប្រការ ១ និង ប្រការ ២ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com